# នៅមុខខ្លោងទ្វាររោងចក្រ

ឈុតទី 4/6




អង្គការ
ពលកម្ម
អន្តរជាតិ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា


ប៊ូប៊ូប៊ូរររររ....!!!
ថៃ...មើលជួយគ្នាផង!!! ឱ្យលឿន...លឿនឡើង !!! ទៅយកទឹកកក និង ប្រអប់ថ្នាំមោះ ..... ឯងម៉េចហើយ..? ត្រូវកន្លែងណាមិញ?
ខ្ញុំអត់អីទេ......ខ្ញុំ....ខ្ញុំដូចជា គោកត្រូវក្បាល....អូ....អូយ!.... ឈឺណាស់.........ក្បាលខ្ញុំមាន ឈាមអត់?


មិនអីទេ....ក្រោកយឺតៗសិនម៉ា ហើយ សំរាកមើល មើល៍....យឺតយឺតៗ.....
ឥឡូវសាកដកដង្ហើមឱ្យវែងៗ ហើយកុំកំរើក....
អ្នកណាចោលស្បោងអស់នេះទៅលើដីអញ្ចឹង? ចុះធុងសំរាមនៅឯណា ម៉េចបានជាគ្មានអ្នកណាប្រើ?!
ហើយស្អីនេះ? ឱ្យតែខ្វះខាតគ្មានអីផងហ្នឹង...ក្រៅពី...បង់រុំរបួសដែលគេប្រើរួច ហើយនិង...សំបកដបថ្នាំលាងរបួស.....
នេះ...អ្នកស្រី..... ប្រអប់ថ្នាំសង្គ្រោះបឋម....
អ្នកណាជាអ្នកទទួលខុសត្រូវការងារនេះ?!
រឿង រ៉ាវដដែលៗ....នៅពេលដែលកម្មករមានរបួស គ្មាននរណាយកចិត្តទុកដាក់ទេ....
....អ៊ុយ...ក្បាលខ្ញុំ ....អ៊ុយ...ឈឺណាស់ ....អ៊ុយ........
ថ្នាក់គ្រប់គ្រងមិនបានយកចិត្តទុកដាក់ពីសុខភាព និង សុវត្ថិភាពការងាររបស់កម្មករនោះទេ គេខ្វល់ខ្វាយតែពីលុយប៉ុណ្ណោះ! មើលតែប្រអប់ថ្នាំនេះទៅដឹងហើយ ....ឱ្យតែខ្វះខាត គ្មានបានការអីទាំងអស់! បើខ្ញុំឡើងធ្វើជាអនុប្រធានសហជីពវិញ ខ្ញុំនឹងធានាថា ប្រអប់នេះនឹងមានថ្នាំពេញជានិច្ច!
ពូកុសលនិយាយត្រូវហើយ....ពួកយើងត្រូវការឱ្យគេជួយនៅពេលដែលយើងមានគ្រោះថ្នាក់នៅកន្លែងធ្វើការ ការងារជាច្រើននៅក្នុងរោងចក្រយើងនេះ ដូចជាមិនសូវមានសុវត្ថិភាពទាល់តែសោះ....


ព្រឹកស្អែកឡើងនៅរោងចក្រ
ភ្លើងឆេះ
អស់អាលឹង!!!


បងកុសល! ឱ្យលឿនឡើង! ជួយខ្ញុំផង! ...... នោះ! នៅខាងនោះ មានក្រណាត់ ក្រាស់ៗ ច្រើន ទៀត!
ចាប់ជួយយកមក គ្របភ្លាមម៉ោ!!!
ពេលពន្លត់ភ្លើងរួច
ដារ៉ាមិនបាច់មកដណ្ដើមយកស្នាដៃទេ....ខ្ញុំជាអ្នកទទួលខុសត្រូវពន្លត់ភ្លើង នេះមុនពេលដែលឯងម៉ោទៅ ទៀត....សំណាងហើយដែលយើង នៅទីនេះ ហើយឃើញហេតុការនេះទាន់......


ខ្ញុំដឹងហើយ.....ឧបករណ៍ពន្លត់អគ្គិភ័យទាំងអស់នេះ ត្រូវតែត្រួតពិនិត្យឱ្យបានទៀងទាត់ ទើបបាន យើងទាំងអស់គ្នាត្រូវព្យាយាមរកវិធានការយ៉ាងណាការពារកុំឱ្យមានឧបទ្ទវហេតុកើតឡើង ប្រសើរជាង យើងចាំស្តាយក្រោយពេលដែលរឿងរ៉ាវអស់នោះវាបានកើតឡើងរួចទៅហើយ
នៅថ្ងៃបន្ទាប់
ម៉េចហើយប្អូនស្រី...? គ្រាន់បើបន្តិចហើយមែនទេ? មិនចាំបាច់បារម្ភអីទេ អ្នកគ្រប់គ្នាសុទ្ធតែឃើញឈាមហូរចេញពីក្បាលឯង បងនឹងធ្វើឱ្យថ្នាក់គ្រប់គ្រងយល់ថា នៅពេលដែលកម្មករណាម្នាក់ ទទួលរងរបួសធ្ងន់ធ្ងរដូចករណីដូចឯងថ្ងៃនេះ....ពួកគេត្រូវតែផ្តល់ជាប្រាក់សំណងដល់កម្មករយើង!
មិនអីទេពូកុសល....របួសខ្ញុំ មិនជាធ្ងន់ធ្ងរអីប៉ុន្មានទេ ថ្ងៃស្អែកនេះខ្ញុំអាចសំរាកមិនបាច់ទៅធ្វើការបានទេ ហើយបើចាំនៅស្អែក ខ្ញុំរាងធូរបន្តិចវិញហើយនោះ ខ្ញុំអាចត្រលប់ចូលធ្វើការវិញបាន
ចុះឯងចាំបាច់ទៅប្រញាប់ចូលធ្វើការវិញធ្វើអី សារ៉េតអើយ...សំរាកម៉ាអាទិត្យទៅ ឥឡូវមិនបាច់បារម្ភទេ ...ហើយបានថាគ្មាននរណាកាត់លុយឯងម៉ារៀលទេ.... ថ្នាក់គ្រប់គ្រងនឹងត្រូវបង់លុយឱ្យឯងតាមរយៈពួកបង ដើម្បីឱ្យឯងអាចសំរាក និង ដើរលេងបានទៀតផង!
ពូកុសល.....ថ្នាក់គ្រប់គ្រងរោងចក្រ គេបានយល់ព្រមចេញថ្លៃព្យាបាលឱ្យសារ៉េតទៅហើយ ហើយពួកយើងទាំងពីរនាក់សុទ្ធតែដឹងច្បាស់ណាស់ថា នេះជាអ្វីដែលច្បាប់ការងារតម្រូវឱ្យធ្វើ
នៃ ស៊ីណា....នាងខ្វះកន្លែងទៅណាស៊ីក៏យ៉ាងម៉េចហ្នឹង? ទៅធ្វើអ្នកមានបំណងល្អនៅកន្លែងផ្សេងមិនបានទេអី?
ខ្ញុំដូចជាមិនយល់ពូកុសលឯងសោះ.....ក្បាលខ្ញុំអត់មានដេរីផង ហើយពេទ្យប្រចាំការនៅរោងចក្រយើងប្រាប់ខ្ញុំថា ស្អែកនេះខ្ញុំត្រូវទៅឱ្យគាត់ពិនិត្យមើលរបួសម្តងទៀត....
ពេទ្យប្រចាំរោងចក្រទៅដឹងអ្វីទៅ! អាវត្តតែឈ្មោះជាពេទ្យ...តាមពិតទៅពីដូចតែពួកធ្វើការនៅផ្នែកគ្រប់គ្រងអញ្ចឹង...ធ្វើយ៉ាងម៉េច ឱ្យតែពួកយើងជាកម្មករល្ងង់ និង ធ្វើការជូនវា! ឯងមើល តែរឿងដែលកើតឡើងនៅក្នុងថ្ងៃនេះទៅដឹងហើយ.....បំពង់ពន្លត់ភ្លើងអស់ទាំងនោះនៅតែសំបកទទេ ហើយមិនដែលត្រួតពិនិត្យដល់ទៅជាង២-៣ឆ្នាំហើយណោះ....!


តែឥឡូវនេះយើងអាចធ្វើអ្វីបានទៅ? បើគ្រោះថ្នាក់វាកើតឡើងរួចបាត់ទៅហើយហ្នឹង!
ខ្ញុំដឹង ប៉ុន្តែយើងគួរតែជួយបង្ការគ្រោះថ្នាក់ទាំងអស់នោះកុំឱ្យកើតឡើងទៅលើអ្នកដទៃទៀតនៅថ្ងៃមុខ...ក្រុមការងារដែលមកពីអង្គការ អាយឡូ ឬមកពីក្រសួងការងារ អាចផ្តល់យោបល់ទៅអ្នកគ្រប់គ្រងរោងចក្ររបស់យើងបាន ហើយបន្ទាប់មកយើងក៏អាចធ្វើការជាមួយផ្នែកគ្រប់គ្រងដើម្បី អនុវត្តគំរោងការងាររបស់គេបានផងដែរ!
ពីរ បីថ្ងៃបន្ទាប់មកនៅការិយាល័យលោកប្រធាន
ឯងនិយាយនេះដូចជាត្រូវម្យ៉ាងដែរ ស៊ីណា....
បាទ...មានរោងចក្រជាច្រើនកំពុងតែចាប់ផ្តើមយល់ថាអ្វីដែលខាងខ្ញុំកំពុងព្យាយាមធ្វើ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករ
ខ្ញុំយល់ហើយ..... មានឧបទ្ទវហេតុតូចៗ ជាច្រើនបានកើតឡើងនៅក្នុងរោងចក្រ ដែលឧបទ្ទវហេតុ ទាំងអស់នោះអាចបណ្តាលឱ្យកើតទៅជារឿងរ៉ាវធ្ងន់ធ្ងរបាន..... ខ្ញុំសង្ឃឹមថាខាងអាយឡូនឹងអាចផ្តល់យោបល់មកឱ្យរោងចក្រយើង ដើម្បីឱ្យយើងអាចឈានដល់ការគោរពស្តង់ដាអន្តរជាតិបាន
ចាប់តាំងពីការចុះត្រួតពិនិត្យរោងចក្រលើកដំបូង ខាងខ្ញុំបានកត់សំគាល់ឃើញនូវចំនុចមួយចំនួន ដែលខាងខ្ញុំគិតថាសំខាន់ និងត្រូវដោះស្រាយ
...ហើយនឹងធ្វើឱ្យលក្ខខណ្ឌការងារមានលក្ខណៈ ប្រសើរឡើងសំរាប់អ្នកគ្រប់គ្នា


ក្រុមការងារដើរមើលជុំវិញរោងចក្របន្តទៀត
ឥឡូវនេះខ្ញុំគិតថា យើងគួរតែដើរមើលជុំវិញរោងចក្រនេះបន្តិចមើល ដើម្បីឱ្យយើងអាចធ្វើការ ចង្អុលបង្ហាញនូវចំនុចទាំងឡាយណា ដែលគួរតែត្រូវធ្វើការកែសម្រួលនោះ....
....អញ្ចឹងពួកយើងសុទ្ធតែយល់ស្រប ជំរុញឱ្យក្រុមកម្មករ ទាមទារសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវសុខភាព និងសុវត្ថិភាពការងារល្អនៅក្នុងរោងចក្រយើងនេះហើយមែនទេ?
ប្រាកដជាអញ្ចឹងហើយ.....តែ ចុះរឿងនេះ មានផលប្រយោជន៍អីទៅពួកយើងដែរទៅ?
ពួកឯងកុំល្ងង់ពេក....បើកម្មករគាំទ្រយើងឱ្យឡើងធ្វើជាអនុប្រធានសហជីព តើអ្នកណាខ្លះដែល នឹងត្រូវទទួលប្រយោជន៍នោះ.....មិនមែនជាពួកឯងនេះទេឬ?


ពូកុសល....តើពូឯងយកចិត្តទុកដាក់ពីកម្មករ រឺក៏បារម្ភតែពីរឿងបោះឆ្នោតអនុប្រធានសហជីពនេះទេ?
ពូឯងស្តាប់ខ្លួនឯងមើលទៅ....បានត្រឹមតែនិយាយឈ្លោះប្រកែកគ្នា ធ្វើឱ្យរឿងរ៉ាវកាន់តែស្មុគស្មាញឡើង ប្អូនស្រីអ្នា...ឯងរងគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយអាចជាត្រូវបញ្ជូនទៅមន្ទីរពេទ្យ ដើម្បីធ្វើការវះកាត់ទៀតផងណា! តោះ! ទៅជួបប្រជុំ ក្រុមកម្មករជាមួយខ្ញុំ....
ពីរបីនាទីបន្ទាប់មក កណ្ដឹងប្រកាសអាសន្នអគ្គិភ័យក៏រោទិ៍ឡើង
រឺរឺង....!!!
ភ្លើងឆេះហើយ! ភ្លើងឆេះហើយ!
ប្រញាប់ជួយគ្នា ឱ្យឆាប់ឡើង! ពួកឯងចង់ឱ្យរោងចក្រនេះឆេះរលាយរលត់អស់ឬក៏យ៉ាងម៉េចហ្នឹង?!


ពីរបីនាទីបន្ទាប់មក


អ្នកស្រីប្រធាន! ខ្ញុំសូមទៅសំអាត និង ធ្វើរបាយការណ៍ អំពីករណីភ្លើងឆេះនេះសិន....
ខ្ញុំរកឃើញមូលហេតុដែលបង្កឱ្យភ្លើងឆេះ ឆេះឡើងហើយ
....ហើយបើគ្មានកុសលដែលមានសេចក្តីក្លាហាន និងមិនគិតគូរដល់អាយុជីវិតខ្លួនឯង ដើម្បីទៅចុចកណ្ដឹងផ្ដល់សញ្ញាអគ្គិភ័យ ពេលនេះពួកយើងប្រហែលជាមិនបានមកឈរនៅកន្លែងនេះ ផងទេក៏មិនដឹង....


!??
ដើម្បីថ្លែងអំណរគុណ និង បញ្ជាក់ពីសេចក្តីក្លាហាន របស់កុសល លោកថៅកែរោងចក្របាន សូមឱ្យខ្ញុំចេញមុខជូនវិញ្ញាបនបត្រមួយជូនដល់កុសល ព្រមទាំងផ្លែឈើមួយកន្ត្រកនេះផងដែរ........ កុសល លោកមានពាក្យពេចន៍អ្វីចង់និយាយខ្លះទេ?
ខ្ញុំគិតថា អ្វីដែលខ្ញុំបានធ្វើនេះគ្មានអ្វីគួរឱ្យអស្ចារ្យនោះឡើយ.... ឱ្យតែអ្នកដែលមានតំណែង និង តួនាទីដូចខ្ញុំ នោះក៏គេនឹងធ្វើដូចគ្នាហ្នឹង.....
ពូកុសល....ពូបានជួយសង្គ្រោះការងារពួកយើង ហើយប្រហែលជាបានជួយជីវិតពួកយើងខ្លះទៀតផង!
ពួកយើង.... យើងនាំគ្នាគាំទ្រពូកុសល! គាំទ្រពូកុសល! គាំទ្រពូកុសល......!
គាំទ្រពូកុសល
អរគុណ...អរគុណបងប្អូនទាំងអស់គ្នា....ខ្ញុំសូមសន្យានឹងបងប្អូនថា បើបងប្អូនបោះឆ្នោតជ្រើសរើសខ្ញុំធ្វើជាអនុប្រធានសហជីព ខ្ញុំនឹងប្រឹងប្រែងធ្វើការបំរើបងប្អូនឱ្យដូចកាលដែលខ្ញុំចិត្តជួយរោងចក្រនិង បងប្អូនទាំងអស់គ្នាឱ្យរួចផុតពីគ្រោះថ្នាក់អគ្គិភ័យលើកនេះអញ្ចឹងដែរ..
ចាស៎ ខ្ញុំសូមអរគុណលោកច្រើនណាស់កុសលឡូ.....ប៉ុន្តែ ខ្ញុំចង់ជំរាបឱ្យអ្នកគ្រប់គ្នាដឹងផងដែរ យើងទើបតែរកឃើញថា ការឆេះអគ្គិភ័យលើកនេះ កើតឡើងដោយសារតែអំពើទុច្ចរិតប្រហែល


ដោយសារណាម្នាក់ ឬ មនុស្សមួយចំនួនដែលជក់បារី នៅក្នុងកន្លែងដែល
មានបង្កឱ្យមានគ្រោះថ្នាក់ ដែលការជក់បារីនៅក្នុងកន្លែងអស់នោះ
ត្រូវបានហាមឃាត់ដាច់ខាត
តើអ្នកណាទៅ ដែលបង្កឱ្យភ្លើងឆេះ
នេះឡើង? ប្រាប់ពួកខ្ញុំផងមើល!!!
ខ្ញុំនឹងជំរាបឱ្យអ្នកទាំងអស់គ្នាដឹង នៅពេល
ដែលពួកយើងរកឃើញ

**សេចក្ដីថ្លែងអំណរគុណ**

សៀវភៅនេះត្រូវបានរៀបរៀង និង ផលិតដោយបុគ្គលិករបស់អង្គការ ILO ***គម្រោងរោងចក្រកាត់ដេរប្រសើរ នៅកម្ពុជា*** លោក ខនស៍ ប៊ុយ, លោក ជុំ ជស្ស៊ី, អ្នកស្រី នូ គារី, កញ្ញា ណាង ចន្ធី, អ្នកស្រី យស់ សុធា និង លោក វុធ លីណុ ។ អង្គការ ILO សូមថ្លែងអំណរគុណជាពិសេសចំពោះ លោក នីក វូដ (Navigator Communications) កញ្ញា ម៉ុន ជស្ស៊ីកា, លោក ម៉ៃខ សុគន្ធ, លោក ឈើន ស៊ីណាក់, អ្នកនាង ស្វែង សុជាតា, លោក ពៅ គឹសាន់, កញ្ញា វ៉ាដា លោក អន់ សុភី និង កញ្ញា ថៃ ពេញជីមី (ជាតួសម្តែង ដែលត្រូវបានគេថតយកជារូបភាព) សំរាប់ការចូលរួមវិភាគទានរបស់ពួកគេ ដើម្បីផលិតជាសៀវភៅ នេះឡើង ។

**វិចិត្រករដោយ**

លោក ហូសេ អ៊ែនស៊ីណា
Jose Encinas jose@tonle.net

**ឧបត្ថម្ភថវិកាដោយ**

សៀវភៅនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភថវិកា តាមរយៈកិច្ចព្រមព្រៀងរួមគ្នារវាង ទីភ្នាក់ងារ សហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ USAID និង អង្គការ ILO ***គម្រោងរោងចក្រកាត់ដេរប្រសើរ នៅកម្ពុជា។ គម្រោងរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា*** ត្រូវបានឧបត្ថម្ភដោយវិភាគទានពី:

អ្នកផ្ដល់ជំនួយ

- រាជរដ្ឋាភិបាលកម្ពុជា
- ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
- សហភាពសហព័ន្ធសហជីពជាតិកម្ពុជា
- សហភាពការងារកម្ពុជា
- ធនាគារពិភពលោក
- ក្រុមនៃអ្នកបញ្ជាទិញអន្តរជាតិ

សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង:

***រោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***

**អង្គការពលកម្មអន្តរជាតិ**

លេខ៥ ផ្លូវលេខ៣២២ បឹងកេងកង១

ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ២៦៤២

ទូរស័ព្ទ : (+៨៥៥) ២៣ ២១២ ៨៤៧

(+៨៥៥) ២៣ ២២០ ៣៦២

ទូរសារ : (+៨៥៥) ២៣ ២១២ ៩០៣

អ៊ីម៉េល : betterfactories@ilo.org

វ៉ិបសាយ: www.betterfactories.org/ilo

# សារសំខាន់ៗដកស្រង់ពីឈុតនេះ

- ការពារសុខភាព និងសុវត្ថិភាព ប្រសើរជាងព្យាបាល
- ប្រុងប្រយ័ត្នជាប់ជានិច្ចទាំងនៅកន្លែងធ្វើការ និងនៅតាមផ្លូវទៅ និងមកពីធ្វើការ
- អ្នកគ្រប់គ្រង សហជីព និងកម្មករគួរធ្វើការរួមគ្នា ដើម្បីសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ
- ពាក់សំភារៈការពារផ្ទាល់ខ្លួននៅពេលចាំបាច់